# ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ

ជាតិ សាសនា ព្រះមហាក្សត្រ

**សំណុំរឿង**

លេខ: ០៥៨/០០២/២០០៣

ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៣

**សេចក្តីសម្រេច**

លេខ: ០៥២/០០៣/២០០៣ កបធ.ច

ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ
- បានឃើញសំណើលេខ ១១៧ រស ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៣ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៣
- បានឃើញប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដែលអគ្គ-លេខាធិការដ្ឋានរដ្ឋសភាបានផ្ញើមកក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃ ខែ ឆ្នាំដដែល

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី ២ ឃ្លាទី ១ ដែលចែងថា " បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាស

ឱ្យប្រើ ។ " និង មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្ម ប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ជាការស្របតាមរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ការសំរេចអំពីធម្មនុញ្ញភាពលើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដោយផ្អែកតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី ២ ឃ្លាទី ២ ដែលចែងថា " ក្រុមប្រឹក្សាធម្ម-នុញ្ញត្រូវសំរេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ថាតើ ច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ខាងលើ ស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ ។ "
- យល់ឃើញថា ប្រការ ៣៦ ថ្មី និង ប្រការ ៣៦ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ខុសគ្នាត្រង់ការបន្ថែមលើប្រការ ៣៦ (ចាស់ ) នូវវាក្យខ័ណ្ឌមួយថ្មីទៀតដែលចែងថា " វិធីបញ្ចេញមតិដោយលើកដៃ ឬ ដោយបោះឆ្នោតចំហខាងលើនេះអាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ។ "
- យល់ឃើញថា ប្រការ ៣៨ ថ្មី និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ខុសគ្នាត្រង់ប្រការ ៣៨ ថ្មី ប្តូរដាក់ ពណ៌ស សំគាល់ថា ព្រម មុនដាក់ ពណ៌ខៀវ សំគាល់ថា មិនព្រម ។ អត្ថន័យទាំងអស់នៅដដែល

ការប្តូរដាក់មុនក្រោយ ដើម្បីឱ្យមានភាពរលូន និង ពិរោះស្តាប់ " ព្រម " " មិនព្រម " " អនុបវាទ " មិនមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ប្រការ ៣៦ ថ្មី មិនមានចែងច្បាស់លាស់អំពីនីតិវិធីដែលត្រូវប្រើប្រព័ន្ធអេឡិចត្រូនិចក្នុងការបោះឆ្នោតចំហ ។ ការមិនបានចែងនីតិវិធីអាចនឹងបណ្តាលឱ្យមានការប៉ះពាល់ដល់ប្រការ ៣៨ ថ្មី ដែលមានបញ្ជាក់ត្រង់ថា " អាជ្ញាសភាកាន់ហិបឆ្នោតដើរទទួលប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា " ។ ទោះបីមានបច្ចេកវិទ្យាដល់កំរិតខ្ពស់ក៏នៅមានការលំបាកក្នុងការបំពេញល័ក្ខខ័ណ្ឌឱ្យមានអាជ្ញាសភាប្រតិបត្តិការងារដូចនេះបានឡើយ

- យល់ឃើញថា ដើម្បីឱ្យស្របនឹងរដ្ឋធម្មនុញ្ញ ត្រង់មាត្រា ៥ គួរប្រើភាសាខ្មែរ ដែលមាន សម្រាប់ជំនួសពាក្យបរទេស គឺពាក្យ អសន្យាណូ ជំនួសពាក្យ " អេឡិចត្រូនិច " ។

**សំរេច**

**មាត្រា ១.-** វិសោធនកម្មលើប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដែល រដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៣ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ២ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែកុម្ភៈឆ្នាំ ២០០៣ នាសម័យ ប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយ មានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន